**Program:** ឃាតកម្មមុនចូលគេង

**Topic:** Kenneth KIMES Jr. (ម្តាយនិងកូនប្រុស ដែលជាឃាតក)

**Categories:** Crime Investigation

**Check: done**

**Content by:** Prey Reung



---

**Hook**
សូមស្វាគមន៍មកកាន់CamID Podcast!

ខណៈពេលដែលម្តាយគ្រប់រូប កំពុងតែបង្រៀនកូនអោយចេះ ABC និងបង្រៀនអោយចេះចងស្បែកជើងទៅរៀន តែបែរជាមានម្តាយម្នាក់ ដែលជាឃាតក នៅអាមេរិក បានបង្រៀនអោយកូនរបស់គេធ្វើខ្លួន អោយក្លាយទៅជាឃាតកទៅវិញ។

"កូនធាប់ផ្ទាក់ឡើង រួចធាប់ទៅដុសធ្មេញ អាងនឹងយកសាកសព យកទៅញាត់ក្នុងកាបូបឲ្យលឿនៗ" នេះគឺជាពាក្យមួយឃ្លា ដែលកូនជាឃាតក សរសេរក្នុងសៀវភៅរបស់គេ ស្របពេលដែលគេកំពុងជាប់ពន្ធធនាគារ។

**Intro**

នេះប្រហែលជាហេតុការណ៏ដំបូង ដែលអ្នកទាំងអស់គ្នាទើបតែស្តាប់ហើយ។

ជារឿងចម្លែកមួយ នៅសហរដ្ឋអាមេរិក ដែលម្តាយ ដែលជាអ្នកមានតួនាទីអប់រំកូន អោយដើរផ្លូវល្អ បែរទៅជាបង្រៀនកូនអោយសម្លាប់មនុស្សទៅវិញ ហើយសម្លាប់មនុស្សដែលមានវ័យ៨២ឆ្នាំទៀត ដែលវាមើលទៅ ហាក់ដូចជាសាហាវឃោឃៅពេកហើយ។

រឿងរ៉ាវរបស់ពួកគេទាំងពីរ ត្រូវបានកូនប្រុសគាត់ម្នាក់ទៀត សរសេរជាសៀវភៅ ដែលមានចំណងជាភាសាអង់គ្លេសថា Son Of The Grifter ។

មុននឹងនាំអ្នកទាំងអស់គ្នាទៅស្គាល់កូន របស់គេ ព្រៃរឿងសូមនិយាយពីប្រវត្តម្តាយជាឃាតកជាមុនសិន ថាតើគេជាអ្នកណា ហើយមានប្រវត្តសម្លាប់មនុស្ស និងឧក្រិដ្ឋកម្មបែបណាខ្លះ? ហើយហេតុអ្វី បានជាពួកគេទាំងពីរ រួមគ្នាសម្លាប់មនុស្សចាស់ អាយុដល់ទៅ៨២ឆ្នាំទៅវិញ?

**Body:**

រឿងរ៉ាវនេះ ផ្តើមចេញពីម្តាយម្នាក់ ដែលមានឈ្មោះថា Sante Kimes។

Sante កើតនៅក្នុងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៣៤ នៅក្នុងរដ្ឋ Oklahoma លើទឹកដីប្រទេសសហរដ្ឋអាមេរិក។

ឪពុករបស់នាងឈ្មោះ Rattan មានសញ្ជាតិដើមជាឥណ្ឌាខាងកើត ចំណែកឯម្តាយរបស់នាង ឈ្មោះMaryជាជនជាតិIreland។

Sante គឺជាកូនទីបី ក្នុងចំណោមបងប្អូនទាំង៤នាក់ក្នុងគ្រួសារ។ នៅពេលដែលគ្រួសារនាង បានទៅរស់នៅរដ្ឋCalifornia។ ឪពុករបស់នាង បានរត់ចោលគ្រួសារ រីឯម្តាយរបស់នាង បានទាល់ច្រក ក៏ទៅធ្វើជានារីរកស៊ីផ្លូវភេទ។ មូលហេតុនេះហើយ ទើបធ្វើអោយ Sante និងបងប្អូនរបស់នាង ទៅរស់នៅក្នុងមណ្ឌលកុមារកំព្រា ទាំងវ័យក្មេង។

នៅពេលដែលSante គឺជាកូនទី៤ ដែលឪពុកម្តាយបោះបង់ចោល នាងកំពុងតែរៀនថ្នាក់ទី៧ ហើយគ្រានោះ មានគ្រួសារមួយដែលមានត្រកូល Sandra Chambers បានយកSanteទៅចិញ្ចឹម។

ក្រោយមក គ្រួសារនេះ ក៏បានប្តូរទៅរស់នៅទីក្រុង Carson រដ្ឋ Nevada។ នៅទីនោះ Sante ធ្វើបានល្អមែនទែន ទៅលើការសិក្សាថ្នាក់វិទ្យាល័យរបស់នាង។ មិនតែប៉ុណ្ណោះនាងថែមទាំងធ្វើជាប្រធានថ្នាក់ទៀតផង។

ផ្ទុយទៅវិញ បើទោះបីជាការសិក្សារបស់នាង ល្អយ៉ាងណា ក៏មិនអាចកែប្រែចិត្តគំនិតរបស់នាងបានឡើយ ពោលគឺ នៅក្នុងពេលតែមួយSanteចាប់ផ្តើមចេះលួចរបស់របរ តាមហាង ហើយនិងលួចគ្រឿឥតកាតឪពុកចិញ្ចឹមរបស់នាងទៀតផង។

ថ្ងៃមួយ ម្តាយបង្កើតរបស់នាង បានមកដល់ទីក្រុង Carson រួចក៏ជួបនាង ហើយម្តាយរបស់នាង ចង់យកនាងទៅរស់នៅជាមួយគាត់វិញ ក៏ប៉ុន្តែSanteមិនព្រមទៅនោះឡើយ។

បីខែក្រោយ បន្ទាប់ពីនាងចប់ថ្នាក់វិទ្យាល័យ Sante បានរៀបការជាមួយសង្សាសម្លាញ់ចិត្តរួមវិទ្យាល័យម្នាក់ ឈ្មោះថា Lee Powers តែពីរបីខែក្រោយមក ពួកគេក៏បានបែកបាក់គ្នា។

ក្នុងឆ្នាំ១៩៥៦ Sante បានរៀបការជាមួយបុរសម្នាក់ទៀតឈ្មោះថា Edward Walker។ យ៉ាងណាស្នេហារបស់ពួកគេ បានបញ្ចប់ក្នុងឆ្នាំ១៩៦១ នៅពេលដែលSante ត្រូវបានប៉ូលិស ចាប់ពីបទលួចរបស់របរអេកមកដទៃ។ ពួកគេទាំងពីបានបែកបាក់គ្នា ដោយបន្សល់ទុកកូនប្រុសម្នាក់ឈ្មោះ Kent Walker។

សូមបញ្ជាក់ផងដែរថា កូនប្រុសដំបូងរបស់នាង មិនរស់នៅជាមួយនាងនោះទេ ហើយក៏មិនមែនជាឃាតកបន្ទាប់ពីនាងដែរ។ Kent Walker នេះហើយគឺជាអ្នកនិពន្ធសៀវភៅSon Of The Grifter នេះឯង។

ចាប់តាំងពីពេលបែកបាក់គ្នាមក Sante បានក្លាយខ្លួនទៅជាឧក្រិដ្ឋជន យ៉ាងរហ័សមែនទែន។ នាងក៏បានក្លាយទៅជា ជនបោកប្រាស់ និងចោរផ្លន់ទៀតផង។

នាងតែងតែឈរបោកមនុស្សគ្រប់គ្នា ដើម្បីយកលុយ តាមរយៈការឃោសនាពីនេះពីនោះ និងបំផ្លៃពណ៌មានមិនពិត ដើម្បីអោយគេជឿនាង។ មួយវិញទៀត Sante ថែមទាំងដុតបំផ្លាញ ទ្រព្យសម្បត្តិ ដើម្បីយកប្រាក់ធានារ៉ាប់រងទៀតផង។

រហូតដល់ថ្ងៃមួយ នាងបានបោក ជនអន្តោប្រវេសន៍ខុសច្បាប់ អោយមកធ្វើជាអ្នកបម្រើរបស់នាង។ Sante បានយកជនអន្តោប្រវេសន៍ទាំងនោះ មកស្នាក់នៅផ្ទះរបស់នាង។

នាងអោយពួកគេ ធ្វើការងារផ្សេងៗ នៅក្នុងផ្ទះ ស្រេចតែអំពើចិត្តរបស់នាង បើពុំនោះទេ នាងនឹងគំរាមផ្ញើង អោយទៅស្រុកកំណើតរបស់ខ្លួនជាមិនខាន។ នេះគ្រាន់តែជាល្បិចបោកប្រាស់របស់Sante ១ ក្នុងចំណោម ១០០ជំពូកតែប៉ុណ្ណោះ។

ក្នុងចំណោមនោះ មានល្បិចបោកប្រាស់មួយ ដែលគួរអោយគត់សម្គាល់ជាងគេ គឺនាងបានបន្លំខ្លួន ធ្វើជាតារាសម្តែងស្រីម្នាក់ នៅក្នុងសហរដ្ឋអាមេរិកដែលមានឈ្មោះថា Elizabeth Taylor ដែលមើលទៅSanteដូចនាងតែបន្តិចប៉ុណ្ណោះ។

ក្រោយមក នាងក៏បានរៀបការជាមួយគូស្នេហ៍ទី៣របស់នាង ដែលមានឈ្មោះថា Kanneth Kimes ដែលជាម្ចាស់សណ្ឋាគារ និងជាមហាសេដ្ឋីម្នាក់ ប្រចាំប្រទេសសហរដ្ឋអាមេរិក។

ព្រៃរឿងសូមបញ្ជាក់ផងដែរថា មិនមានប្រភពណាមួយ បង្ហាញពីទំនាក់ទំនង មុនពេលដែលគេរៀបការនោះទេ ហើយតាមពិតទៅKenneth Kimes ក៏ជាមនុស្សម្នាក់ដែលញៀនស្រាផងដែរ។

ពួកគេទាំងពីរ មានកូនប្រុសម្នាក់ឈ្មោះថា Kenneth Kimes Jr. ដែលកូនម្នាក់នេះហើយ ដែលរួមដៃគ្នា ជាមួយម្តាយរបស់ខ្លួនក្នុងការប្រព្រឹត្តបទល្មើសជាច្រើន រួមទាំង ករណីឃាតកម្មចំនួន២ផងដែរ។

គ្រួសាររបស់ពួកគេ មានផ្ទះជាច្រើនកន្លែង ដូចជានៅ រដ្ឋ Las vegas រដ្ឋCalifornia នៅលើកោះHawaii និងនៅរដ្ឋBahamas ផងដែរ។

ក្រោយពីរៀបការរួច Sante បានចាយវាយខ្ជះខ្ជាយទ្រព្យសម្បត្តិ និងលុយកាក់របស់ប្តីនាងមែនទែន ជាពិសេស ទៅលើថ្លៃឈ្នួលមេធាវីទៅលើរឿងក្តី ទាក់ទងនឹងការយកមនុស្ស មកធ្វើជាទាសក។

ពោលគឺនៅខែសីហា ឆ្នាំ១៩៨៥ Sante និងប្ដីរបស់នាង ត្រូវបានចាប់ខ្លួន ពីបទយកមនុស្សមកធ្វើជាទាសករ។

Sante បានពន្ធធនាគារអស់រយះពេល៥ឆ្នាំ រីឯប្ដីរបស់នាង ក៏បានធ្វើលិខិតសូមអភ័យទោស និងព្រមទទួលការកាត់បន្ថយសុរាផងដែរ។

ឪពុក និងកូនប្រុសរបស់គេគឺKennneth Jr បានចំណាយជីវិតរស់នៅជាធម្មតា លុះដល់ពេលដែលSante ចេញពីពន្ធធនាគារវិញ ទើបរឿងមិនប្រក្រតីបានកើតឡើង។

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៤  Kenneth Kimes ដែលជាប្ដីរបស់Sante បានស្លាប់ដោយសារតែជម្ងឺគាំងបេះដូង។

ងាកមកមើលSanteវិញ នាងនៅតែបន្តប្រព្រឹត្តអំពើឆបោក និងចាប់ជំរិតដដែរ។ មិនតែប៉ុណ្ណោះ ក៏មានវត្តមានកូនប្រុសរបស់នាង គឺKennth Kimes Jr នៅក្នុងឃាតកម្មផងដែរ។

ឃាតកម្មដំបូង ដែលម្ដាយនិងកូនប្រព្រឹត្ត គឺនៅក្នុងឆ្នាំ១៩៩៨  ដែលជនរងគ្រោះឈ្មោះថា David Kazdin។ រឿងកើតឡើងដោយសារតែ David បានទិញផ្ទះប្ដីរបស់ Sante នៅរដ្ឋLas Vegas នៅឆ្នាំ១៩៧០។

នៅពេលដែលប្ដីនាងស្លាប់ទៅ Sante បានទ្រព្យប្ដីនាងមកវិញ ដោយSante Kimes បានបញ្ចុះបញ្ចូល អ្នកសារការីម្នាក់ ដើម្បីក្លែងបន្លំហត្ថលេខារបស់ David លើពាក្យសុំខ្ចីប្រាក់ចំនួន ២៨០.០០០ ដុល្លារ ដោយផ្ទះនេះ ជាវត្ថុបញ្ចាំតែប៉ុណ្ណោះ។

នៅពេលដែលលោកDavidដឹង លោកក៏បានគម្រាមថា នឹងធ្វើអោយសារធាណះជន ដឹងលើពីពណ៌មាននេះ។

Sante ក៏បានដឹង រួចក៏ជួលអោយកូនរបស់នាង គឺKenneth Jr អោយទៅសម្លាប់David ចោល ដោយKenneth Jr បានបាញ់David ពីក្រោយចំក្បាល បណ្ដាលអោយស្លាប់។

សាកសពរបស់លោក ត្រូវបានគេរកឃើញនៅក្នុងធុងសំរាម រីឯអាវុធដែលបាញ់សម្លាប់នោះ គឺមិនបានរកឃើញនោះទេ ព្រោះគេបានទម្លាក់ចោលក្នុងលូទឹកស្អុយបាត់ទៅហើយ។

ជនរងគ្រោះបន្ទាប់របស់ពួកគេ គឺជាមនុស្សចាស់ អាយុ៨២ឆ្នាំ ដែលមានឈ្មោះថា Irene Silverman ពោលគឺនៅក្នុងឆ្នាំ១៩៩៨ ដដែរ Sante ជាមួយកូនរបស់នាង Kenneth Jr បានរៀបផែនការសម្លាប់លោកយាយ Irena ដើម្បីប្រើប្រាស់អត្តសញ្ញាណប័នរបស់គាត់ ក្នុងគោលបំណងធ្វើជាម្ចាស់អចលនទ្រព្យជំនួសគាត់ និងថែមទាំង ចង់យកភូមិគ្រឹះរបស់គាត់ ដែលមានតម្លៃ៧.៧លានដុល្លារទៀតផង។ ក្នុងឃាតកម្មនេះ សាកសពរបស់គាត់មិនត្រូវបានរកឃើញនោះទេ។

ក្រុមប៉ូលិសស៊ើបអង្កេតFBI បានទូរស័ពខលទៅសួរនាំSante ប៉ុន្តែSante បានប្រាប់ប៉ូលិសថា មិត្តភិក្តរបស់គាត់ម្នាក់ទៀតឈ្មោះថា Stan Patterson គឺជាអ្នកសម្លាប់។ មកដល់ចំណុចនេះ ហើយដែលអំពើព្រៃផ្សៃរបស់ Sante និងកូនប្រុស ត្រូវបានបញ្ចប់។

សូមបញ្ជាក់ផងដែរថា Stanគឺជាអ្នក ដែលស្គាល់គ្នាជាមួយSante ហើយក៏ធ្លាប់លក់កាំភ្លើងមួយចំនួនអោយទៅSante ផងដែរ។

ក្រុមប៉ុលិសបានទៅជួប ជាមួយនឹងStan រួចក៏បានផ្ដល់អភ័យឯកសិទ្ធិប្រើប្រាស់កាំភ្លើងដល់គាត់ ដើម្បីជាថ្នូរ ក្នុងការនាំពួកប៉ូលិសទៅជួប Sante។

នៅពេលដែល Stan ទៅជួបពួកគេ ក្រុមប៉ូលិស មិនចាំយូរឡើយក៏ចេញមកចាប់ខ្លួនម្ដាយ និងកូនដែលជាឃាតកភ្លាមៗតែម្ដង។

ប៉ូលិសបានរកឃើញ ពីគម្រោងការសម្លាប់ Irena នៅក្នុងសៀវភៅ Sante ក៏ដូចជាសៀវភៅរបស់លោកយាយ Irenaដែរ រួមទាំងការក្លែងបន្លំហត្ថលេខាដដែរៗ នៅលើសៀវភៅរបស់Santeទៀតផង។

ទីបំផុត ម្តាយ និងកូន ក៏ត្រូវបានបញ្ជូនទៅកាន់តុលាការ។

ការបើកសាវនាការ មិនមែនតែលើរឿងក្តីឃាតកម្ម Irena នោះទេ តែ គឺបទឧក្រិដ្ឋផ្សេងៗដែលពួកគេប្រព្រឹត្តចំនួន១១៧ថែមទៀត ហើយសុទ្ធតែមានទោសទាំងអស់។

ក្រោយមក ពួកគេត្រូវបានបញ្ជូនទៅកាន់រដ្ឋ California ដើម្បីរង់ចាំសាវនាការ ក្នុងក្តីឃាតកម្មលោក David ថែមទៀតផង។

កំឡុងពេលដែលម្តាយ និងកូន កំពុងជាប់នៅក្នុងរឿងក្តីរបស់ David ស្រាប់តែ Kenneth Jr ក៏បានធ្វើការសំទោសចំពោះមុខតុលាការ ហើយនិងបានសារភាព ពីគម្រោងការសម្លាប់ទាំងប៉ុន្មានទៅកាន់តុលាការថា  នៅពេលដែលម្តាយរបស់គេ បានផ្ទង់កាំភ្លើងទៅលើ Irena ពេលកំពុងតែដេកភ្លាមនោះ Kenneth Jr បានច្របាច់កគាត់ រហូតដល់ស្លាប់ រួចហើយយកសាកសពគាត់ ដាក់ចូលកាបូបដើម្បីបោះចោលនៅក្នុងធុងសំរាមមួយ នៅទីក្រុងHoboken នៃរដ្ឋNew Jersey។ Kenneth Jr ធ្វើការសារភាពបែបនេះ ដើម្បីអោយរួចពីទោសប្រហារជីវិត។

ម្យ៉ាងវិញទៀត Kennth Jr មិនមែនសារភាពពីការសម្លាប់David និងIrena តែប៉ុនហ្នឹងទេ គេថែមទាំងសារភាពថា គេនិងម្តាយរបស់ខ្លួន ក៏បានរួមគ្នាប្រព្រឹត្តអំពើឃាតកម្មទី៣ដែរ ដែលមានជនរងគ្រោះឈ្មោះថា Sayed Bilma Amed។

គេបានសារភាភាពថា Sayed គឺជាអ្នកវិនិយោគ ធនាគារម្នាក់ ដែលជាជនជាតិឥណ្ឌា។ មូលហេតុដែលពួកគេសម្លាប់នោះគឺ Sayed បានបដិសេដមិនអោយប្រាក់កម្ចីទៅកាន់Sante។

ដូច្នេះពួកគេក៏បានចាប់ Sayed ជ្រមុជទឹក អោយលង់ទឹកស្លាប់រួច ហើយយកសាកសពគេទៅបោះចោលនៅសមុទ្រ។

ទាក់ទងនិងឃាតកម្មនេះ Sante បានបដិសេដថា នាងមិនបានចូលរួមក្នុងឃាតកម្មលោក Sayed នោះទេ ហើយបាននិយាយថា កូនរបស់នាងសារភាព ដើម្បីអោយរួចពីទោសប្រហារជីវិតតែប៉ុណ្ណោះ។

ចំណែកឯសាកសពលោកSayed មិនត្រូវបានរកឃើញនោះឡើយ។ ហើយម្តាយ និងកូនទាំងពីរ ក៏មិនបានជាប់ទោសទៅលើឃាតកម្មលោកSayed នោះឡើយ ព្រោះមិនមានភស្តុតាង បញ្ជាក់ថាគេ ជាឃាតកពិតប្រាកដនោះទេ។

ចុងក្រោយ ឃាតកជាម្តាយ Sante Kimes បានជាប់ពន្ធធនាគារអស់រយះពេល១២៥ ស្មើនឹង១សតវត្ស២៥ឆ្នាំ ទៅលើក្តីឃាតកម្មរបស់លោកយាយ Irena និងជាប់ពន្ធធនាគារអស់មួយជីវិត ទៅលើក្តីឃាតកម្មរបស់លោកDavid។

នាងត្រូវបានគេបញ្ជូន អោយទៅពន្ធធនាគារ Bedford Hill នៅទីក្រុង New York។ លុះដល់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ Sante បានស្លាប់ដោយសារតែ រោគពាទក្នុងអាយុ៧៩ឆ្នាំ។

ចំណែកឯកូនរបស់គេ Kenneth Kimes Jr បានជាប់ពន្ធធនាគារអស់មួយជីវិត ពីបទសម្លាប់David នៅឯរដ្ឋCalifornia។

មកដល់ពេលនេះ Kenneth Jr មានអាយុ៤៥ឆ្នាំ ហើយគេក៏កំពុងតែសរសេរសៀវភៅមួយ ដែលរៀបរាប់អំពីជីវិតរបស់គេ កំអោយយុវជនជំនាន់ក្រោយយកគំរូតាម។

ពាក្យមួយឃ្លាដែល Kennth Jr បានសរសេរក្នុងសៀវភៅរបស់គេគឺ ”ដើម្បីគេចផុតពីទោសប្រហារជីវិត ខ្ញុំបានល្មើសកិច្ចព្រមព្រៀងជាមួយម្តាយខ្ញុំ ហើយបានសារភាព។ ម្តាយខ្ញុំ

មិនសហការជាមួយតុលាការឡើង សូម្បីតែជួយសង្គ្រោះជីវិតខ្ញុំក៏អត់ដែរ។ នាង បានទទូចថា យើងត្រូវបន្តការភូតកុហករបស់យើង។ ដោយឃើញបែបនេះ ខ្ញុំក៏ផ្តល់សក្ខីកម្មប្រឆាំងនឹងនាង ដើម្បីជួយសង្គ្រោះយើងទាំងពីរ"។

**Ending:**
ក្រោយពីប្រិយមិត្តទាំងអស់គ្នាបានស្តាប់រឿងរ៉ាវខាងនេះ ហើយយើងអាចកត់សម្គាល់ថា ក្នុងនាមជាអាណាព្យាបាល គួរតែអប់រំ អោយកូនក្លាយទៅជាបុគ្គលគំរូក្នុងសង្គម មិនត្រូវអោយកូនធ្លាក់ក្នុងរណ្តៅអាវជ័យបែបនេះឡើយ។

ទំនួលខុសត្រូវនៅក្នុងគ្រួសារ ពិតជាសំខាន់ខ្លាំងណាស់ ជាពិសេសសម្រាប់ក្មេងៗ ការដែលខ្វះភាពកក់ក្តៅ និងការថែទាំពីគ្រួសារ នឹងអាចជះឥទ្ធិពលទៅលើសុខភាពផ្លូវចិត្តរបស់កុមារនៅថ្ងៃខាងមុខ។

បើខ្លួនឯងជ្រុលជាប្រព្រឹត្តអំពើអាក្រក់ទៅហើយ គួរតែគិតគូដល់កូនៗ កុំអោយកូនយកដើរតាមគន្លងរបស់ខ្លួន។ នេះសូម្បីតែពេលជាប់ទោស ក៏ប្រកែកយកតែរួចខ្លួនឯងដែរ។

យ៉ាងណាក៏ដោយ ការប្រព្រឹត្តអំពើឆបោក និងសម្លាប់មនុស្ស ដើម្បីផលប្រយោជន៍ខ្លួន ក៏មិនមែនជាដំណោះស្រាយដែលត្រឹមត្រូវសម្រាប់ជីវិតឡើយ
មិនត្រឹមតែប៉ុណ្ណោះ អំពើមនុស្សឃាតក៏មិនត្រូវកើតមាននោះដែរ
គឺមិនអាចកើតព្រោះហេតុផលណាក៏ដោយ។

នៅក្នុងសង្គមមួយ គឺតែងតែមានមនុស្សល្អ និងអាក្រក់ដែលមិនបានបែកចែកគេទឡើយ ដូចនេះ គ្រប់កាលៈទេសៈ យើងគ្រប់គ្នាគឺត្រូវចេញតាំងស្មារតី និងប្រយ័ត្នការពារខ្លួនជានិច្ច។

តែទោះជាយ៉ាងណាក៏ដោយ ព្រៃរឿងសង្ឃឹមថា រឿងព្រៃផ្សៃបែបនេះ
នឹងមិនកើតមានឡើងក្នុងសង្គមយើងឡើយ។
សូមស្តាប់ដោយត្រិះរិះពិចារណា!
យើងនិងជួបគ្នាម្តងទៀត ក្នុង CamID Podcast ក្រោយ។ សម្រាប់ពេលនេះ សុបិនល្អ និងរាត្រីសួស្តី។

Links and Resources

https://www.dailymail.co.uk/
https://murderpedia.org/
https://www.nytimes.com/
https://www.oxygen.com/
https://criminalminds.fandom.com/